# សង្ខេបលទ្ធផលការឃ្លាំមើលសវនាការ







| ល.រ | បរិយាយ - តុលាការ (សរុប១៧៥ករណី) | ករណី | ភាគរយ |
|---|---|---|---|
| ១ | រារាំងមិនឲ្យចូល ឬបណ្ដេញចេញពីបន្ទប់សវនាការ (សាធារណៈជន) | ១៤២ | ៨១.១% |
| ២ | រារាំងមិនឲ្យចូល ឬបណ្ដេញចេញពីបន្ទប់សវនាការ (អ្នកសារព័ត៌មាន) | ១១៦ | ៦៦.៣% |
| ៣ | មិនបានពន្យល់លំអិតអំពីសិទ្ធិមានមេធាវី ឬសិទ្ធិការពារខ្លួន | ៦៩ | ៤០% |
| ៤ | មិនបានពន្យល់លំអិតអំពីសិទ្ធិមិនឆ្លើយ | ៩៥ | ៥៤% |
| ៥ | មិនបានពន្យល់លំអិតអំពីសិទ្ធិមិនបង្ខំឲ្យសារភាពកំហុស | ៩៤ | ៥៤% |
| ៦ | មិនបានពន្យល់លំអិតអំពីសិទ្ធិការសន្មត់ទុកជាមុនថាគ្មានទោស | ៩៤ | ៥៤% |
| ៧ | ជនជាប់ចោទពាក់ឯកសណ្ឋានពន្ធនាគារអំឡុងពេលសវនាការ | ១៣២ | ៧៥.៤% |
| ៨ | ជនជាប់ចោទជាប់ខ្នោះដៃអំឡុងពេលសវនាការ | ៧២ | ៤១% |
| ៩ | ព្រះរាជអាជ្ញាស្រែកសម្លុត នៅពេលជនជាប់ចោទមិនឆ្លើយ | ០៧ | ៤% |
| ១០ | ចៅក្រមជំនុំជម្រះបានប្រាប់ឲ្យជនជាប់ចោទសុំទោស | ៨១ | ៤៦.៣% |
| ១១ | ចៅក្រម/តំណាងអយ្យការសម្ដែងអាកប្បកិរិយាសម្លុតគំរាមជនជាប់ចោទ | ១៨ | ១០.៣% |
| ១២ | ចៅក្រម/តំណាងអយ្យការចាកចេញពីបន្ទប់អំឡុងពេលសវនាការ | ៨២ | ៤៧% |
| ១៣ | ចៅក្រម/តំណាងអយ្យការប្រើទូរស័ព្ទអំឡុងពេលសវនាការ | ៣៣ | ១៩% |
| ១៤ | តុលាការលើកពេលប្រកាសសាលក្រម | ១៧០ | ៩៧% |
| ១៥ | តុលាការលើកពេលប្រកាសសាលក្រមដោយមិនបញ្ជាក់កាលបរិច្ឆេទ | ៩៤ | ៥៤% |
| ១៦ | តុលាការបានបន្ថែមបទល្មើសថ្មីនៅពេលប្រកាសសាលក្រម | ១៣៧ | ៧៨% |

❶ **សមាគមអាដហុក** បានចូលរួមឃ្លាំមើលសវនាការសរុប ១៧៥ករណី ស្ថិតនៅ២០រាជធានី-ខេត្ត ដែលមានករណីសិទ្ធិមនុស្ស ៤៥.១% ករណីសិទ្ធិដីធ្លី១៨.៣% និងករណីស្ត្រី-កុមារ៣៦.៦%។ ហើយក្នុងនោះមាន បទឧក្រិដ្ឋ ១៣៧ករណី និង បទមជ្ឈិម ៣៨ករណី ដែលមានជនរងគ្រោះជាជនជាប់ចោទ សរុបចំនួន ១,១៦៥នាក់ និងដើមបណ្ដឹងជាជនរងគ្រោះចំនួន៤៥២នាក់។

❷ **១៤២ នៃ១៧៥ករណី** ជនជាប់ចោទត្រូវតុលាការសំរេចឃុំខ្លួនបណ្ដោះអាសន្ន ហើយបើគិតដល់ថ្ងៃបើកសវនាការជំនុំជម្រះ មានជនជាប់ចោទ៨០ករណី ត្រូវបានតុលាការឃុំខ្លួនបណ្ដោះអាសន្នលើសពី៦ខែរហូតដល់២៤ខែ ។

❸ **តុលាការនៅតែមានភាពយឺតយ៉ាវបើកសវនាការ** រហូតដល់ចន្លោះពី មួយម៉ោងជាង ទៅពីរម៉ោង បើប្រៀបធៀបជាមួយម៉ោងក្នុងដីកាកោះហៅ និងម៉ោងពេលបើកសវនាការជំនុំជម្រះពិតប្រាកដ ។

❹ **តុលាការនៅតែមានភាពយឺតយ៉ាវ** ក្នុងការចេញលិខិតអញ្ជើញមេធាវីតំណាងគូភាគី ដើម្បីចូលរួមក្នុងនីតិវិធីទាំងនៅតំណាក់កាលព្រះរាជអាជ្ញា តំណាក់កាលស៊ើបសួរ និងតំណាក់កាលជំនុំជម្រះ គឺលិខិតអញ្ជើញមកដល់ត្រឹមតែមួយថ្ងៃ ឬពីរថ្ងៃមុនពេលចាប់ផ្ដើមនីតិវិធីប៉ុណ្ណោះ ។

❺ **ភាគច្រើនជាពិសេសករណីវិវាទដីធ្លី** រវាងសហគមន៍ជាមួយនឹងអ្នកមានទ្រព្យ-មានអំណាច ចៅក្រមជំនុំជម្រះ មិនបានអនុញ្ញាត (មិនបានកោះហៅ) ឲ្យសាក្សីដោះបន្ទុកចូលរួមធ្វើសក្ខីកម្ម ទោះបីជាមេធាវីបានដាក់ស្នើក៏ដោយ(ឧទាហរណ៍ដូចជាករណីវិវាទដីធ្លីនៅខេត្តកោះកុង និងខេត្តព្រះសីហនុ ជាដើម) ។

សមាគមអាដហុក
ADHOC

❻ **មានរហូតដល់ជាង៩០%** តុលាការមិនបានជូនដំណឹងអំពីដីកាសម្រេច ដូចជា ដីកាសន្និដ្ឋានស្ថាពរ និងដីកាដំណោះស្រាយ។
❼ **តុលាការពេលខ្លះកោះហៅកូនក្តី មិនអញ្ជើញមេធាវី** ប៉ុន្តែបើបានអញ្ជើញមេធាវី មិនកោះហៅកូនក្តី ចូលរួមនៅតំណាក់កាលព្រះរាជអាជ្ញា តំណាក់កាលចៅក្រមស៊ើបសួរ...។

## អនុសាសន៍

1. ក្រសួងយុត្តិធម៌ ពិនិត្យដាក់វិធានការណ៍ច្បាស់លាស់ ចំពោះការអនុវត្តន៍របស់ចៅក្រម និងតំណាងអយ្យការ ទាំងឡាយណា ដែលផ្ទុយនឹងគោលបំណង មាត្រា២០៨ និងមាត្រា២០៩ នៃនីក្រមតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានចែងអំពីថេរវេលា នៃការឃុំខ្លួនបណ្តោះអាសន្ន ។ បើយោងរបាយការណ៍បានបង្ហាញថា ការឃុំខ្លួនបណ្តោះអាសន្ន ដែលមានថិរវេលាលើសពី៦ខែ រហូតដល់ជាង២៤ខែមានចំនួន៨០ករណី នៃករណីសរុប១៧៥ ។
2. ក្រសួងយុត្តិធម៌ពិនិត្យ និងដាក់ពិន័យរដ្ឋបាលធ្ងន់ធ្ងរដល់ចៅក្រម និងតំណាងអយ្យការដែលមានការយឺតយ៉ាវចំពោះពេលវេលាបំពេញភារកិច្ចការងារ បើកសវនាការជំនុំជម្រះ ។ យោងតាមរបាយការណ៍បានបង្ហាញថា មានភាពយឺតយ៉ាវខ្លាំងពីជាងមួយម៉ោង រហូតដល់ពីរម៉ោង បើប្រៀបធៀបម៉ោងពេលបានកំណត់ក្នុងដីកា និងម៉ោងពេលបើកសវនាការជាក់ស្តែង។
3. ក្រសួងយុត្តិធម៌ ពិនិត្យដាក់វិធានការណ៍ច្បាស់លាស់ ចំពោះការអនុវត្តន៍របស់ចៅក្រម និងតំណាងអយ្យការទាំងឡាយណា ដែលមានការយឺតយ៉ាវក្នុងការចេញលិខិតអញ្ជើញមេធាវី និងភាគីចូលរួមក្នុងសវនាការជំនុំជម្រះ ។
4. ក្រសួងយុត្តិធម៌ ពិនិត្យដាក់វិធានការណ៍ច្បាស់លាស់ ចំពោះការអនុវត្តន៍របស់ចៅក្រម និងតំណាងអយ្យការទាំងឡាយណាដែលខកខាន មិនបានអញ្ជើញមេធាវីចូលរួមអមកូនក្តី ដើម្បីស្តាប់ចម្លើយកូនក្តីនៅតំណាក់កាលព្រះអាជ្ញា និងចៅក្រម ស្របតាមនីតិវិធី ។
5. ក្រសួងយុត្តិធម៌ ពិនិត្យដាក់វិធានការណ៍ច្បាស់លាស់ ចំពោះការអនុវត្តន៍របស់ចៅក្រម និងតំណាងអយ្យការទាំងឡាយណាដែលខកខានមិនបានជូនដំណឹងអំពីដីកាសម្រេចដូចជាដីកាសន្និដ្ឋានស្ថាពរ និងដីកាដំណោះស្រាយ ។
6. ចៅក្រម-តំណាងអយ្យការ ពិចារណាក្នុងការប្រើពាក្យ ឬនិយាយពីភាពមានឬគ្មានទោសដល់ជនជាប់ចោទ មុនពេលចេញសាលក្រម ជាពិសេសដូចជា ប្រាប់ឲ្យជនជាប់ចោទសុំទោស ។
7. ចៅក្រមពិនិត្យ-ពិចារណា អំពីសិទ្ធិរបស់ជនជាប់ចោទដូចជា ជនជាប់ចោទមានពាក់ឯកសណ្ឋានពន្ធនាគារ និងដៃជាប់ខ្នោះ ក្នុងអំឡុងពេលសវនាការជំនុំជម្រះ ។
8. ចៅក្រមពន្យល់ប្រាប់ជនជាប់ចោទ-ជនរងគ្រោះ ឲ្យបានច្បាស់លាស់ អំពីសិទ្ធិដែលត្រូវទទួលបានដូចជា សិទ្ធិមានមេធាវី សិទ្ធិមិនឆ្លើយ សិទ្ធិមិនបង្ខំឲ្យសារភាពកំហុស និងសិទ្ធិសន្មត់ទុកជាមុនថា គ្មានកំហុស សិទ្ធិដឹងពីបទចោទ សិទ្ធិដឹងការបរិច្ឆេទ-ទីកន្លែងប្រព្រឹត្តបទល្មើសជាដើម ។
9. ក្រសួងយុត្តិធម៌ ពិនិត្យដាក់វិធានការណ៍ច្បាស់លាស់ ចំពោះគ្រប់សាលាដំបូង ក្នុងការបើកចំហរដល់សាធារណៈជន និងអ្នកសារព័ត៌មានបានចូលស្តាប់សវនាការសាធារណៈ ដោយគ្មានការហាមឃាត់ និងបណ្តេញចេញ ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនង ៖
លោក **ស៊ឹង សែនករុណា** អ្នកនាំពាក្យសមាគមអាដហុក ០៨៦ ៣២៤ ៦៦៦
០៨៩ ៦៦៦ ៣១២